00198488

C22/I/53

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### លិខិតដាក់ពាក្យ សុំការពិចារណាឡើងវិញ ដោយផ្អែកលើ អង្គហេតុពេញលេញ

នាងខ្ញុំឈ្មោះ សេង ធារី ភេទស្រី សូមគោរពជូនអង្គចៅក្រមបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

*សូមអង្គចៅក្រមជាទីគោរពដ៏ខ្ពង់ខ្ពស់ជ្រាប!*

**កម្មវត្ថុ** : សំណើដាក់ពាក្យសុំការពិចារណាឡើងវិញដោយផ្អែកលើអង្គហេតុពេញលេញ

នាងខ្ញុំ សរសេរលិខិតនេះក្នុងនាមនាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី, ដែលពេលនេះនាងខ្ញុំលែងមានមេធាវី ទៀតហើយនោះ, សូមសំណូមពរដល់អង្គចៅក្រមមេត្តាពិចារណាឡើងវិញចំពោះសេចក្តីសំរេចដែលបានធ្វើឡើងកាលពីម្សិលមិញ, គឺនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨, ទាក់ទងទៅនឹងសិទ្ធិរបស់នាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យដោយខ្លួន នាងខ្ញុំផ្ទាល់ នៅក្នុងអង្គបុរេជំនុំជម្រះ ទាក់ទិនទៅនឹងការសួរដេញដោលស្តីពីបញ្ហាយុត្តាធិការ។

នាងខ្ញុំអំពាវនាវ សុំអោយមានការពិចារណាឡើងវិញ ស្តីពីបញ្ហានេះដោយផ្អែកទៅលើអង្គហេតុពេញលេញ។ ជាអកុសល, អង្គបុរេជំនុំជម្រះមិនបានទទួល អង្គហេតុពេញលេញ ដើម្បីធ្វើអោយមានការចាប់អារម្មណ៍ មុនពេលសំរាកពីការសួរដេញដោល និងការសំរេចចិត្ត របស់អង្គចៅក្រមទេ ដោយហេតុថា នាងខ្ញុំមិន ត្រូវបានអនុញ្ញាតិអោយនិយាយឡើយ។ ប្រសិនបើនាងខ្ញុំមានឱកាសបាននិយាយ វីក៏មេធាវីរបស់នាងខ្ញុំ ដែលត្រូវបានបញ្ឈប់ពីការងារ បាននិយាយនោះ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04/ JULY / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.FRY

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 07 / 2008
ម៉ោង (Time/Heure): 14 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

នាងខ្ញុំ រឺយើងខ្ញុំ នឹងបានបញ្ជាក់ជូនអង្គ ចៅក្រម អោយបានច្បាស់ថា នៅក្នុងលិខិតរបស់នាងខ្ញុំ និងលិខិតប្រគល់សិទ្ធិអំណាច (ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨) ដែលធ្វើសំណូមពរអោយការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ លោក នី ចាន់ឌី ជាមេធាវីរបស់នាងខ្ញុំនោះ, នាងខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ថា នាងខ្ញុំមានបំណង ចង់ «តំណាងរូបនាងខ្ញុំ និង/រឺ មេធាវីរបស់នាងខ្ញុំអាចតំណាងនាងខ្ញុំនៅគ្រប់ដំណាក់កាលនៃដំណើរ ការនីតិវិធី ជាពិសេសនៅក្នុង ... អង្គបុរេជំនុំជម្រះនេះ ...» (សូមអាននៅក្នុងលិខិតភ្ជាប់) ។ នាងខ្ញុំ បានបញ្ឈប់មេធាវីរបស់នាងខ្ញុំ ដោយសារតែការតំណាងនោះពុំមានប្រសិទ្ធិភាព ។

នាងខ្ញុំសូមទាញចំណាប់អារម្មណ៍របស់អង្គចៅក្រមផងដែរថា នាងខ្ញុំធ្លាប់បាន បង្ហាញមុខ និងអាចថ្លែងប្រាស្រ័យទៅកាន់អង្គចៅក្រម នៅក្នុងសវនាការអង្គបុរេជំនុំជម្រះនេះចំនួនពីរលើករួចមកហើយ គឺនៅក្នុងសវនាការ លោក នួន ជា និង លោក ខៀវ សំផន ។

នាងខ្ញុំ សូមធានាថាសេចក្ដីថ្លែងការណ៍របស់នាងខ្ញុំ គឺជាទឡ្ហីករណ៍ដែលមានអង្គហេតុនិងតាមផ្លូវច្បាប់ស្របទៅនឹងបញ្ហាដែលកំពុងសួរដេញដោល ដោយនាងខ្ញុំយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាចំពោះកង្វល់ទាំងឡាយដែលអាចកើតមាន ចំពោះការចូលរួមដែលមិនធ្លាប់មានពីមុនមកក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ។ អង្គចៅក្រមក៏អាចរំលឹកឡើងវិញដែរថា នាងខ្ញុំបានលើកឡើងនូវកង្វល់ទាំងនោះនៅក្នុងការថ្លែងប្រាស្រ័យរបស់នាងខ្ញុំជាលើកដំបូងនៅក្នុងសវនាការលោក នួន ជា ។

នាងខ្ញុំសូមសង្កត់ធ្ងន់ទៅលើទស្សនៈជំទាស់របស់ចៅក្រម រ៉ូវ៉ាន់ ដោននីង ដែលបានលើកឡើងថា : «ខ្ញុំធ្វើនេះដោយពឹងផ្អែកទៅលើប្រសិទ្ធិភាពដែលបញ្ហានេះ អាចឈានទៅរកការបញ្ចប់

00198490

C22/I/53

សិទ្ធិរបស់នាងក្នុងការទាមទារតាមវិធានផ្ទៃក្នុង ២៣.១(ខ) តទល់នឹងជនត្រូវចោទ ។ ជាលទ្ធផល តាមទស្សនៈរបស់ខ្ញុំ វានឹងក្លាយទៅជាដំណើរការមិនយុត្តិធម៌ដោយយោងទៅតាមវិធាន ផ្ទៃក្នុង ២១.១(ក) ក្នុងការដែលមិនអនុញ្ញាតិអោយភាគីដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងប្រាស្រ័យ នៅក្នុង តុលាការ» ។

នាងខ្ញុំសូមអំពាវនាវដល់អង្គចៅក្រម សូមមេត្តាពិចារណាឡើងវិញ ក្នុងការអនុញ្ញាតិ អោយនាងខ្ញុំ មានសំឡេងក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ។ ប្រសិនបើមិនដូចនោះ រឺប្រសិនបើ នៅតែតំកល់សេចក្តីសំរេចនោះ, ដោយផ្អែកលើអង្គហេតុថ្មីៗ, មានន័យថាជាការរំលោភលើសិទ្ធិជា មូលដ្ឋានរបស់នាងខ្ញុំ ក្នុងនាមជាភាគីមួយនៅក្នុងសវនាការ ។

ភ្នំពេញ, ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨

សេង ធារី

00198491

C22/I/53

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យប្រគល់សិទ្ធិដល់មេធាវីតំណាងដោយអាណត្តិ

នាងខ្ញុំឈ្មោះ **សេខ ច័ន្ទធារី** អាយុ ៣៩ ឆ្នាំ សញ្ជាតិ ខ្មែរ មានទីលំនៅ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០១) នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា ។

## សូមគោរពចូលមក

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សូមទានជ្រាប ។

នាងខ្ញុំមានកិត្តិយស សូមជំរាបជូនលោកសហចៅក្រមស៊ើបអង្កេត នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេត្តាជ្រាបថា នាងខ្ញុំបានសំរេចជ្រើសរើសលោកមេធាវី **នី ចាន់ឌី** ដែលជាសមាជិកគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងដែលបច្ចុប្បន្នជាមេធាវី នៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (អាស័យដ្ឋានៈ ផ្ទះលេខ ៥៥សេ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ) ហើយដែលបានចុះបញ្ជីទទួលស្គាល់ នៅអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិដល់នាងខ្ញុំ នៅគ្រប់តំណាក់កាលនៃនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អាស្រ័យហេតុនេះ សូមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេត្តាជ្រាបជាព័ត៌មាន និងទទួលស្គាល់មេធាវីរបស់នាងខ្ញុំ ចាប់ពីពេលនេះតទៅ ។

ភ្នំពេញ ថ្ងៃទី.៣០.ខែ.មករា....ឆ្នាំ២០០៨..

បានឃើញ និងយល់ព្រមៈ
មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

AVOCAT
ATTORNEY AT LAW

**នី ចាន់ឌី**

ស្នាមមេដៃស្តាំ
ភាគីដើមបណ្តឹងរដ្ឋប្បវេណី

**សេខ ច័ន្ទធារី**

00198492

C22/I/53

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សូមគោរពចូលមក:

## សហចៅក្រមស៊ើបអង្កេត

## នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នាងខ្ញុំឈ្មោះ **សេង ចំនួនធារី** អាយុ ៣៥ឆ្នាំ សញ្ជាតិ ខ្មែរ មានទីលំនៅ នៅសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១) នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា ។

នាងខ្ញុំមានកិត្តិយស សូមជំរាបជូនលោកសហចៅក្រមស៊ើបអង្កេត នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេត្តាជ្រាបថា នាងខ្ញុំបានសំរេចជ្រើសរើស លោកមេធាវី **នី ចាន់ឌី** ដែលជាសមាជិកគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងដែលបច្ចុប្បន្នជាមេធាវី នៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (អាស័យដ្ឋាន: ផ្ទះលេខ ៥៥សេ ផ្លូវ៣៨០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ) ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិដល់នាងខ្ញុំ នៅគ្រប់តំណាក់កាលនៃនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកមេធាវី **នី ចាន់ឌី** បានចុះបញ្ជីទទួលស្គាល់នៅអង្គភាពជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួចហើយ ។ នាងខ្ញុំសូមស្នើសុំលោកសហចៅក្រមស៊ើបអង្កេត មេត្តាអនុញ្ញាតឱ្យនាងខ្ញុំអាចចូលរួមគ្រប់នីតិវិធី និង ត្រូវការពារដោយមេធាវីរបស់នាងខ្ញុំបាននៅគ្រប់តំណាក់កាលនៃនីតិវិធី ជាពិសេស នៅពេលមានសវនាការរបស់អង្គបុរេជំនុំជម្រះដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ខាងមុខនេះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់ជនត្រូវចោទ **នួន ជា** ដែលអនុញ្ញាតអោយនាងខ្ញុំ និង លោកមេធាវីនាងខ្ញុំ អាចទទួលបាននូវគ្រប់សំនុំរឿងដែលពាក់ព័ន្ធនឹងករណីរបស់នាងខ្ញុំ និងភាគីផ្សេងៗ។

នាងខ្ញុំក៏សូមជំរាបជូនលោកសហចៅក្រមស៊ើបអង្កេតជ្រាបថា នាងខ្ញុំសូមមានវត្តមាននៅក្នុងសាលសវនាការ និងអាចលើកឡើងនូវសេចក្តីថ្លែងការណ៍របស់នាងខ្ញុំនៅពេលខ្លះ ឬត្រូវលើកឡើងដោយលោកមេធាវីរបស់នាងខ្ញុំ ។

នាងខ្ញុំក៏សូមស្នើសូមសហចៅក្រមស៊ើបអង្កេត មេត្តារៀបចំបន្ទប់មួយនៅក្នុងតុលាការ ដែលអាចឱ្យមេធាវីរបស់នាងខ្ញុំអាចរៀបចំ និងជួបជាលក្ខណៈឯកជនជាមួយនាងខ្ញុំ នៅមុនពេលសវនាការណាមួយ។

ភ្នំពេញ ថ្ងៃទី.៣០.ខែ.មករា...ឆ្នាំ២០០.៨.

ស្នាមមេដៃស្តាំ

ភាគីដើមបណ្តឹងរដ្ឋប្បវេណី

**សេង ចំនួនធារី**

សេង ចំនួនធារី

00198493

C22/I/53

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein
des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
01 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction
សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No: 002/14-08-2006
លេខស៊ើបសួរ/Investigation/Instruction
លេខ/No: 002/19-09-2007-ECCC/OCIJ

# សេចក្តីសម្រេចទទួលស្គាល់មេធាវី
# Lawyer's Recognition Decision
# Décision d'accréditation d'avocat

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ២៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា** ឈ្មោះ **អៀង សារី** ឈ្មោះ **អៀង ធីរិទ្ធ** និង ឈ្មោះ **ខៀវ សំផន**

បានឃើញលិខិតប្រគល់សិទ្ធិដល់លោកមេធាវី **នី ចាន់ឌី** ដោយ អ្នកស្រី **សេង ច័ន្ទធារី** ដើមបណ្តឹងរដ្ឋប្បវេណី និង

ការយល់ព្រមរបស់លោកមេធាវីនេះ ចុះថ្ងៃទី៣០ ខែ មករា ឆ្នាំ ២០០៨ ។

## ហេតុដូច្នេះ

១- ទទួលស្គាល់លោកមេធាវី **នី ចាន់ឌី** ជាមេធាវីការពារឲ្យឈ្មោះខាងលើតាមច្បាប់តទៅ។

២- មេធាវី មានសិទ្ធិផ្តល់ជំនួយការច្បាប់ដល់កូនក្តីខ្លួន អាចទំនាក់ទំនងដោយសេរីជាមួយនឹងកូនក្តីខ្លួន និងមានសិទ្ធិចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិច្បាប់។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨

សហចៅក្រមស៊ើបអង្កេត
Co-Investigating Judges
Co-juges d'instruction

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 02 / 2008
ម៉ោង (Time/Heure): 14 : 10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC * CETC

MARCEL Lemonde

យូ ប៊ុនឡេង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00198494

យើង UCH ARUN ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត បានប្រគល់សេចក្តីសម្រេចនេះដល់

នៅថ្ងៃទី 01 ខែ 02 ឆ្នាំ ២០០៨។

**ហត្ថលេខាអ្នកទទួល**

**ហត្ថលេខាអ្នកប្រគល់**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941